របនាសម្ពន្ធ័ស្នើសុំចុះបញ្ជីធ្វើតួបនីយ៍កម្មជាចិនតៃវ៉ាន់របស់ជនបរទេស បន្ទាប់បានរៀបការជាមួយជនតៃវ៉ាន់

ក្រសួងមហាផ្ទៃកែពិនិត្យឡើងវិញនៅខែមីនា ឆ្នាំ ២០១៤

ខ្សែសង្វាក់ស្នើសុំ	ស្ថាបនៈទទួលពិនិត្យ និងដោះស្រាយ	ឯកសារដែលត្រូវប្រគល់អោយ
ការចុះបញ្ជីអាពាហ៍ពិពាហ៍	ការិយាល័យអត្រានុកូលដ្ឋាន	១. អ្នករៀបការនៅក្នុងស្រុក (១) សំបុត្រអាពាហ៍ពិពាហ៍ (២) ឯកសារបញ្ជាក់ស្ដីអត្តសញ្ញាណរបស់ប្ដីប្រពន្ធបរទេសនិងលិខិតបញ្ជាក់សាភាពរៀបការដែលពិនិត្យបញ្ជាក់និងទទួលស្គាល់ពីស្ថានឯកអគ្គរដ្ឋទូតឬស្ថានកុងស៊ុលប្រចាំនៅប្រទេសក្រៅនិងឯកសារបកប្រែជាភាសាចិន (៣) សៀវភៅគ្រួសារឬសៀវភៅស្ថិតិគ្រួសារ (៤) អត្តសញ្ញាណប័ណ្ណពលរដ្ឋនិងត្រា ។ ២. អ្នករៀបការនៅក្រៅស្រុកនៅបរទេស (១) ឯកសារបញ្ជាក់អាពាហ៍ពិពាហ៍ដែលពិនិត្យបញ្ជាក់និងទទួលស្គាល់ពីស្ថានឯកអគ្គរដ្ឋទូតប្រចាំនៅបរទេសនិងឯកសារបកប្រែជាភាសាចិន (២) សៀវភៅគ្រួសារ (៣) អត្តសញ្ញាណប័ណ្ណពលរដ្ឋនិងត្រា (៤) ឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ប្ដីឬប្រពន្ធបរទេស ។ (៥) ប្ដីប្រពន្ធបរទេសដែលមិនអាចត្រឡប់មកតៃវ៉ាន់ចុះបញ្ជី ត្រូវតែភ្ជាប់ជាមួយនូវសេចក្ដីថ្លែងការណ៍ស្ដីពីការប្រើប្រាស់ឈ្មោះចិនដែលពិនិត្យបញ្ជាក់ដោយស្ថានទូត ។ ※ ប្រជាពលរដ្ឋចង់រៀបការជាមួយជនប្រទេសកំណត់ជាពិសេសដែលនៅក្នុងសេចក្ដីប្រកាសនៃក្រសួងមហាផ្ទៃ ត្រូវតែចុះបញ្ជីអាពាហ៍ពិពាហ៍នៅប្រទេសដើមរបស់ប្ដីឬប្រពន្ធបរទេសសិន រួចរៀបចំលិខិតបញ្ជាក់អាពាហ៍ពិពាហ៍និងលិខិតបកប្រែជាភាសាចិន ទៅស្ថានទូតប្រចាំបរទេសស្នើសុំការពិភាក្សាផ្ទាល់មុខ ក្រោយពីឆ្លងកាត់ការការពិភាក្សាផ្ទាល់មុខ រួចយកលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ និងលិខិតបកប្រែជាភាសាចិន ដែលទទួលបញ្ជាក់ពីស្ថានទូតប្រចាំបរទេស ទៅបំពេញបែបបទចុះបញ្ជីអាពាហ៍ពិពាហ៍ ។
ការស្នើសុំទិដ្ឋាការស្នាក់នៅ	បើអ្នកស្នើសុំនៅក្រៅប្រទេស គួរទៅទំនាក់ទំនងផ្ទាល់ជាមួយឯកអគ្គរដ្ឋទូតប្រចាំនៅបរទេស ដើម្បីស្នើសុំទិដ្ឋាការស្នាក់នៅរបស់អ្នកស្នើសុំបើគេបានកាន់ទិដ្ឋាការចុះចត គួរទៅសុំទិដ្ឋាការស្នាក់នៅវិញនៅស្ថានកុងស៊ុលក្រសួងការបរទេស (រួមទាំងទីចាត់ការភាគខាងកណ្ដាល យូនចាណាន ភាគខាងត្បូង ភាគខាងកើតនៃក្រសួងការបរទេស) ។※ បើអ្នកស្នើសុំចង់ចូលដែនចុះចតហួសរយៈពេល៦០ថ្ងៃ ដោយកាន់ទិដ្ឋាការចុះចតហើយទិដ្ឋាការនេះមិនបញ្ជាក់អំពីកំណត់មិនឱ្យពន្យាពេល(NO EXTENSION)ឬមិនអនុញ្ញាតិឱ្យផ្លាស់ប្ដូរទិដ្ឋាការចុះចតទៅជាទិដ្ឋាការស្នាក់នៅទេនោះអ្នកស្នើសុំអាចស្នើសុំប័ណ្ណស្នាក់នៅសំរាប់អាណិកជនពីទីកន្លែងសេវាកម្មនាយកដ្ឋានអន្តោប្រវេសន្តនិងកិច្ចការចេញចូលប្រទេសក្រសួងមហាផ្ទៃផ្អែកតាមមូលហេតុសួរសុខទុក្ខពីញាតសន្តានហើយមិនត្រូវការស្នើសុំប័ណ្ណទិដ្ឋាការស្នាក់នៅពីទីចាត់ការភាគខាងកណ្ដាល យូនចាណាន ភាគខាងត្បូង ភាគខាងកើតនៃក្រសួងការបរទេស ។	១. ១ សំណៅចំលងនៃបញ្ជីស្ថិតិគ្រួសារជនេសុសច្រេិសតរក្នុងស្រុក ដែលបានចេញឱ្យក្នុងរយៈកាល ៣ ខែ ទើបកន្លងទៅ ។(មានចុះបញ្ជីអាពាហ៍ពិពាហ៍ព្រមទាំងបញ្ជាក់ច្បាស់លាស់នូវសញ្ជាតិ ឈ្មោះ និងថ្ងៃ ខែ ឆ្នាំនៃកំណើតរបស់ប្ដីឬប្រពន្ធបរទេស) ។ ២. លិខិតមានចុះបញ្ជីអាពាហ៍ពិពាហ៍ដែលចេញហើយរដ្ឋាភិបាលប្រទេសនៃអ្នកស្នើសុំ (ប្រទេសដែលគ្មានប្រព័ន្ធចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវតែផ្ដល់សំបុត្រអាពាហ៍ពិពាហ៍) ។ ៣. លិខិតបញ្ជាក់និរទោសឬលិខិតបញ្ជាក់ជនសុចរិត ដែលចេញហើយរដ្ឋាភិបាលប្រទេសនៃអ្នកស្នើសុំ ។.(ក្នុងរយៈពេលមួយឆ្នាំចាប់ពីថ្ងៃពិនិត្យបញ្ជាក់ តែមិនលើសរយៈពេលមានប្រសិទ្ធិភាពដែលកំណត់ក្នុងលិខិតបញ្ជាក់) ៤. លិខិតបញ្ជាក់ពិនិត្យសុខភាពពេញលក្ខណ :ចេញឱ្យក្នុងរយពេល ៣ខែ ចេញផ្សាយដោយមន្ទីរពេទ្យពិនិត្យជនបទេសដែលកំណាតដោយក្រសួងសុខាភិបាលនិងសង្គមកិច្ច ឬមន្ទីរពេទ្យមានសមត្ថភាពពេញលក្ខណៈ ។. ៥. លិខិតឆ្លងដែន (រវេលាមានសុខមាលភាព មិនតិចទីង៦ខែ) ។. ៦. រូបថតពិណធម្មជាតិ២សន្លឹកដែលទំហំជា២តឹកីក្នុង៦ខែ ។ (ឯកសារក្នុងប្រការ២-៣ជាឯកសារដែលតាក់តែងនៅបទេស ត្រូវមានការពិនិត្យបញ្ជាក់និងទទួលស្គាល់ពីសំណាក់ស្ថានឯកអគ្គរដ្ឋទូតប្រចាំនៅបរទេស ព្រំទាំងមានឯកសារបកប្រើជាភាសាចិន ឬ ភាសាអង់គ្លេស) ។ (ប្ដីប្រពន្ធបរទេសដែលកាន់វិហ្សាសំចត ប្រសិនបើហួសពីកាលបរិច្ឆេទ ពួកគេត្រូវតែចាកចេញពីតៃវ៉ាន់ ហើយមិនអាចស្នើសុំ ផ្លាស់វិហ្សាស្នាក់នៅក្នុងតៃវ៉ាន់ទេ) ។
ការស្នើសុំលិខិតស្នាក់នៅនៃ អណិកជនបរទេស	ផ្នែកជនបរទេសនៃស្នងការប៉ូលីសកុងឬស្រុកឬក្រុងគ្រប់ក្រុងផ្ទាល់នៃរដ្ឋាភិបាល	១ ,អ្នកចូលដែនដោយកាន់ទិដ្ឋាការស្នាក់នៅ:(១) បំពេញសំណើសុំលិខិតស្នាក់នៅអណិកជនបរទេស១ច្បាប់ រូបថតពណ៌ធម្មជាតិ ១ សន្លឹក មិនទាន់ពាក់មួក(ទំហំតាមកំណត់អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋបច្ចុប្បន្ននេះ) (ដូចជាទំហំនៃអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ សូមទៅទស្សនាវែបសាយពត៌មានពិភពលោកនៃមន្ទីរកិច្ចការអត្រានុកូលដ្ឋាននៃក្រសួងមហាផ្ទៃ http://www.ris. gov.tw/ស្វែងរកពត៌មានអំពីទំហំ) ។ (២) លិខិតឆ្លងដែននិងទិដ្ឋាការស្នាក់នៅ គឺត្រូវការច្បាប់ដើមនិងច្បាប់ចម្លងមួយច្បាប់រៀងៗខ្លួន (ច្បាប់ដើមនឹងសងវិញក្រោយការពិនិត្យមើល) (៣) ឯកសារបញ្ជាក់នូវមូលហេតុស្នើសុំលិខិតស្នាក់នៅ ។ ឧទាហរណ៍ សំណៅដើមនិងថតសៀវភៅគ្រួសាររបស់ប្ដីឬប្រពន្ធតៃវ៉ាន់យើងដែលបានចុះបញ្ជីអាពាហ៍ពិពាហឬអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋបានរៀបចំស្រេច (សំណៅដើមនឹងសងវិញក្រោយការពិនិត្យ) ។ (៤) លិខិតបញ្ជាក់អំពីអាសយ័ដ្ឋានស្នាក់នៅ ។ (៥) សោហ៊ុយប័ណ្ណស្នាក់នៅ : ១ឆ្នាំ១០០០យាន់តៃវ៉ាន់ថ្មី ២ឆ្នាំ២០០០យាន់តៃវ៉ាន់ថ្មី ៣ឆ្នាំ៣០០០យាន់តៃវ៉ាន់ថ្មី) ២. អ្នកដែលចង់ចូលប្រទេសចុះចតហួសរយៈពេល៦០ថ្ងៃដោយកាន់ទិដ្ឋាការចុះចតដែលមានប្រសិទ្ធិភាពហើយទិដ្ឋាការនេះមិនបញ្ជាក់អំពីកំណត់មិនឱ្យពន្យាពេលឬកំណត់ផ្សេងទៀតពីអង្គភាពទិដ្ឋាការ: (១) បំពេញសំណើសុំលិខិតស្នាក់នៅអណិកជនបរទេស ១ច្បាប់ រូបថតពណ៌ធម្មជាតិ ១ សន្លឹក មិនពាក់មួក(ទំហំតាមកំណត់អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋបច្ចុប្បន្ននេះ) (២) លិខិតឆ្លងដែននិងទិដ្ឋាការស្នាក់នៅ គឺត្រូវការច្បាប់ដើមនិងច្បាប់ចម្លងមួយច្បាប់រៀងៗខ្លួន (៣) លិខិតបញ្ជាក់ការពិនិត្យមើលសុខភាពក្នុងរយៈពេល៣ខែ(អ្នកធ្វើត្រួតពិនិត្យសុខភាពនៅក្រៅប្រទេសហើយលិខិតបញ្ជាក់សុខភាពត្រូវពិនិត្យបញ្ជាក់ពីសំណាកស្ថានទូត) (៤) លិខិតបញ្ជាក់អំពីកំណត់ហេតុឧក្រិដ្ឋកម្មជាតិនៃប្រទេសដើម ដែលចេញផ្សាយក្នុង ១ ឆ្នាំថ្មី១នេះ (ត្រូវមានកំណតហេតុក្នុង ៥ឆ្នាំថ្មី១នេះ) ប៉ុន្តែមិនអាចហួសពេលមានប្រសិទ្ធិភាពនៃលិខិតបញ្ជាក់នេះទេ ។(ត្រូវតែទទួលបញ្ជាក់ពីស្ថានទូតប្រចាំបរទេស ហើយត្រូវតែផ្ដល់ភ្ជាប់នូវឯកសារបកប្រែជាភាសាចិន ដែលបានទទួលបញ្ជាក់ពីស្ថានទូតប្រចាំបរទេស ហើយទទួលបញ្ជាក់ពីសារការីក្នុងប្រទេស) (៥) លិខិតបញ្ជាក់ពាក់ព័ន្ធអំពីមូលហេតុស្នើសុំរឿងស្នាក់នៅ ដូចជាកចាត់ចែងសៀវភៅបញ្ជីអត្រានុកូលដ្ឋានសំរាប់ចុះបញ្ជីរៀបការឬអត្តសញ្ញាណប័ណ្ណរបស់ប្ដីឬប្រពន្ធតៃវ៉ាន់យើង ត្រូវមានច្បាប់ដើមនិងច្បាប់ចម្លងមួយច្បាប់ (ច្បាប់ដើម ច្បាប់ដើមនឹងសងវិញក្រោយការពិនិត្យមើល) (៦) លិខិតបញ្ជាក់អំពីអាស័យដ្ឋានស្នាក់នៅ (៧) សោហ៊ុយប័ណ្ណស្នាក់នៅ: ១ឆ្នាំ១០០០យាន់តៃវ៉ាន់ថ្មី ៣ឆ្នាំ៣០០០យាន់តៃវ៉ាន់ថ្មី មួយទៀតត្រូវបង់ប្រាក់២២០០ប្រាក់តៃវ៉ាន់ថ្មីបន្ថែម ។ ※ ក្នុងអំឡុងពេលស្នាក់នៅ ក្នុងករណីបានផ្លាស់ប្ដូរអាសយ័ដ្ឋានស្នាក់នៅ ត្រូវតែទៅស្នើសុំបំពេញបែបបទចុះបញ្ជីការផ្លាស់ប្ដូរអាសយ័ដ្ឋានស្នាក់នៅ ក្នុង ១៥ ថ្ងៃ ក្រោយពីបានផ្លាស់ប្ដូរអាសយ័ដ្ឋាននោះ ។
ការស្នើសុំលិខិតបញ្ជាក់ធ្វើបញ្ជាតួបនីយ៍កម្មជាសញ្ជាតិចិនតៃវ៉ាន់ (ចាប់ពីថ្ងៃស្នើសុំទៅខាងមុខ ស្នាក់បំពេញច្បាប់បន្តហួស៣ឆ្នាំ ហើយ ស្នាក់ហួស១៨៣ថ្ងៃ រាល់ឆ្នាំដោយពិត)	ការិយាលិយកិច្ចការអត្រានុកូលដ្ឋាននៅតំបន់ស្នាក់នៅប្រគល់ឱ្យរដ្ឋាភិបាលទីក្រុងឱវ៉ាទ ខេត្ត(ក្រុង) រួចប្រគល់ក្រសួងមហាផ្ទៃ ដើម្បីចេញផ្សាយ	១. លិខិតស្នើសុំអនុញ្ញាតចូលសញ្ជាតិ(សូមមកដល់ការិយល័យស្នើសុំ ហើយបោះពុម្ពលិខិតស្នើសុំតាមកុំព្យូទ័រ) ព្រមទាំងរូបថត១ សន្លឹក ថតពីខាងមុខ ពណ៌ធម្មជាតិ មិនពាក់មួក បានថតនៅក្នុង ២ ឆ្នាំទើបកន្លងទៅ (ដូចទំហំស្មើនៃរូបថតអត្តសញ្ញាណប័ណ្ណពលរដ្ឋ) ។ ២. លិខិតបញ្ជាក់ការតាំងលំនៅស្របច្បាប់របស់ជនបរទេស ឬលិខិតបញ្ជាក់ការ តាំងលំនៅជារៀងរហូតរបស់ជនបរទេស ។ ៣. លិខិតបញ្ជាក់ការស្នាក់នៅរបស់ជនបរទេស (ត្រូវស្របទៅតាមកំណត់មាត្រាទី៤ក្នុងច្បាប់សញ្ជាតិនិងមាត្រាទី៦នៃបទបញ្ញត្តិអនុវត្តស្ដីពីច្បាប់សញ្ជាតិ) ។ ៤. លិខិតបញ្ជាក់អំពីទ្រព្យសម្បត្តិគ្រប់គ្រាន់ឬការប៉ិនប្រសប់ជាឯកទេសសំរាប់រកស៊ី(យោងតាមមាត្រាទី៧នៃបទបញ្ញត្តិអនុវត្តស្ដីពីច្បាប់សញ្ជាតិ ចំពោះបានប្រគល់លិខិតស្នាក់នៅអចិន្ត្រៃយ៍មិនចាំបាច់ប្រគល់ថមលិខិតបញ្ជាក់ទេ) ។ ៥. សៀវភៅគ្រួសារដែលបានបំពេញបែបបទចុះបញ្ជីអាពាហ៍ពិពាហ៍រួចជាមួយប្ដីឬប្រពន្ធតៃវ៉ាន់យើង(សំណៅដើមនឹងសងវិញក្រោយការពិនិត្យ) ប្ដីឬប្រពន្ធជាជនតៃវ៉ាន់យើងមិនទាន់ចុះបញ្ជីគ្រួសារក្នុងស្រុក ហើយមិនទាន់បំពេញបែបបទចុះបញ្ជីអាពាហ៍ពិពាហ៍រួច ត្រូវតែផ្ដល់ភ្ជាប់ឯកសារបញ្ជាក់អាពាហ៍ពិពាហ៍(ធ្វើនៅក្រៅប្រទេស ត្រូវតែទទួលបញ្ជាក់ពីស្ថានទូតប្រចាំបរទេស បើឯកសារជាភាសាបរទេស ត្រូវតែផ្ដល់ភ្ជាប់នូវឯកសារបកប្រែជាភាសាចិន ដែលបានទទួលបញ្ជាក់ពីស្ថានទូតប្រចាំបរទេស ហើយទទួលបញ្ជាក់ពីសារការីក្នុងប្រទេស) ឯកសារបញ្ជាក់អត្តសញ្ញាណសញ្ជាតិ របស់ប្ដីនិងប្រពន្ធបរទេសនិងតៃវ៉ាន់យើង អ្នកដែលរៀបការនៅក្នុងស្រុក ត្រូវភ្ជាប់មកនូវលិខិតបញ្ជាក់សភាពអាពាហ៍ពិពាហ៍ ដែលមានការពិនិត្យបញ្ជាក់និងទទួលស្គាល់ពីស្ថានឯកអគ្គរដ្ឋទូតឬស្ថានកុងស៊ុលប្រចាំនៅប្រទេសក្រៅនិងឯកសារបកប្រែជាភាសាចិន ។ ៦. លិខិតបញ្ជាក់តាម ប្រការទី៣អំពីគូរស្វាមីជាសញ្ជាតិ ប្រទេសអាចនិយាយភាសាខ្មែរ និងអំណាចតំរូវរបស់ជនតៃវ៉ាន់ ។ ៧. សោហ៊ុយលិខិតបញ្ជាក់ ២០០យាន់តៃវ៉ាន់ថ្មី ។ (សូមផ្ញើប្រាក់តាមប្រៃសណីយ៍ អ្នកទទួលប្រាក់ ក្រសួងមហាផ្ទៃ) ※ កំណត់ត្រាអំពីពេលវេលាចូលចេញពីព្រំដែន កំណត់ត្រាអំពីទោសឧក្រិដ្ឋកម្ម និងសំណៅសៀវភៅគ្រួសារដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍ជាមួយប្ដីឬប្រពន្ធជនតៃវ៉ាន់យើងរបស់អ្នកស្នើសុំ ត្រូវទទួលការត្រួតពិនិត្យពីអង្គការកិច្ចការអត្រានុកូលដ្ឋាន ។ ※ លិខិតបញ្ជាក់នេះមិនអាចចាត់ទុកជាលិខិតបញ្ជាក់បានចូលសញ្ជាតិតៃវ៉ាន់ទេ មានថេរវេលាសុពលភាព ២ ឆ្នាំ អាចប្រើប្រាស់បានសម្រាប់តែនៅពេលអ្នកស្នើសុំទៅស្នើសុំលះបង់សញ្ជាតិប្រទេសដើម ត្រូវការតៃវ៉ាន់ផ្ដល់លិខិតបញ្ជាក់អនុញ្ញាតឱ្យចូលសញ្ជាតិតៃវ៉ាន់ ប្រសិនបើរដ្ឋាភិបាលដើមរបស់អ្នកស្នើសុំមិនកំណត់ថា ត្រូវតែផ្ដល់លិខិតបញ្ជាក់នេះ ទើបអនុញ្ញាតឱ្យលះបង់សញ្ជាតិប្រទេសនោះ ក៏មិនបាច់ស្នើសុំទេ ។(តាមកំណត់ មាត្រាទី ១០ នៃបទបញ្ញត្តិលំអិតនៃច្បាប់សញ្ជាតិជាតិ) ※ ក្រោយពីអ្នកស្នើសុំបានទទួលលិខិតបញ្ជាក់បានលះបង់សញ្ជាតិប្រទេសដើម ក៏អាចបំពេញបែបបទចូលសញ្ជាតិតាមដំណើរការ ស្នើសុំចូលសញ្ជាតិតៃវ៉ាន់ បាន ។
ការស្នើសុំរំសាយសញ្ជាតិប្រទេសដើម	ពិភាក្សាជាមួយរដ្ឋាភិបាលប្រទេសដើម ឬស្ថានក្រុងស៊ុលឬ ។ន្តការតំណាងានប្រគល់សិទ្ធិអោយរបស់ប្រទេសនោះប្រចាំនៅចិន	※ អំពីកិច្ចការស្នើសុំលះបង់សញ្ជាតិប្រទេសដើម សូមពិគ្រោះ និងសួរយោបល់ជាមួយរដ្ឋាភិបាលប្រទេសដើម ឬស្ថានកុងស៊ុល ឬយន្តការតំណាង ប្រគល់សិទ្ធរបស់ប្រទេសនោះ ដែលប្រចាំនៅតៃវ៉ាន់ ។ ※ លិខិតបញ្ជាក់ការលះបង់សញ្ជាតិប្រទេសដើមដែលចេញផ្ដល់ពីស្ថានទូតនិងកុងស៊ុលប្រចាំតៃវ៉ាន់ឬអង្គការតំណាងទទួលសិទ្ធិនៃបរទេស ត្រូវតែទទួលការត្រួតពិនិត្យម្ដងទៀតពីក្រសួងការបរទេស លិខិតធ្វើនៅក្រៅប្រទេស ត្រូវតែទទួលការត្រួតពិនិត្យពីស្ថានទូតប្រចាំបរទេសនិងទទួលការត្រួតពិនិត្យម្ដងទៀតក្រសួងការបរទេស(តាមកំណត់ មាត្រាទី ១៧ នៃបទបញ្ញត្តិលំអិតនៃច្បាប់សញ្ជាតិជាតិ) ។(ចំពោះកិច្ចការទទួលការបញ្ជាក់និងបញ្ជាក់ម្ដងទៀត សូមទាក់ទងជាមួយស្ថានកុងស៊ុលក្រសួងការបរទេស ឬទីចាត់ការភាគខាងកណ្ដាល យូនចាណាន ភាគខាងត្បូង ភាគខាងកើតនៃក្រសួងការបរទេស ដើម្បីសួររកពត៌មាន) ។)
ស្នើសុំធ្វើបញ្ជាតួបនីយ៍កម្ម (ចាប់ពីថ្ងៃស្នើសុំទៅខាងមុខ ស្នាក់បំពេញច្បាប់បន្តហួស ៣ឆ្នាំ ហើយស្នាក់ហួស ១៨៣ថ្ងៃរាល់ឆ្នាំដោយពិត)	ការិយាលិយកិច្ចការអត្រានុកូលដ្ឋាននៅតំបន់ស្នាក់នៅប្រគល់ឱ្យរដ្ឋាភិបាលទីក្រុងឱវ៉ាទ ខេត្ត(ក្រុង) រួចប្រគល់ក្រសួងមហាផ្ទៃ ដើម្បីចេញផ្សាយ	១. លិខិតស្នើសុំចូលសញ្ជាតិ(សូមមកដល់ការិយល័យស្នើសុំ ហើយបោះពុម្ពលិខិតស្នើសុំតាមកុំព្យូទ័រ) ព្រមទាំងរូបថត១ សន្លឹក ថតពីខាងមុខ ពណ៌ធម្មជាតិ មិនពាក់មួក បានថតនៅក្នុង ២ ឆ្នាំទើបកន្លងទៅ (ដូចទំហំស្មើនៃរូបថតអត្តសញ្ញាណប័ណ្ណពលរដ្ឋ) ។ ២. ឯកសារបញ្ជាក់នូវគ្មានសញ្ជាតិ បលះបង់សញ្ជាតិដើម ឬ តាមបទបញ្ញត្តិប្រការទី៩នៃច្បាប់សញ្ជាតិជាតិ លិខិតបញ្ជាក់ការពិតដែលចេញដោយស្ថាបនការបរទេស ។ ៣. លិខិតបញ្ជាក់ការស្នាក់នៅអចិន្ត្រៃយ៍របស់អណិកជនបរទេស ដែលពេញច្បាប់និងមានសុពលភាព ។ ៤. លិខិតបញ្ជាក់ការស្នាក់នៅរបស់ជនបទេស (ត្រូវស្របទៅតាមកំណត់មាត្រាទី៤ក្នុងច្បាប់សញ្ជាតិនិងមាត្រាទី៦នៃបទបញ្ញត្តិអនុវត្តស្ដីពីច្បាប់សញ្ជាតិ) ។ ៥. ការបញ្ជាក់នូវទ្រព្យសម្បត្តិ សមត្ថភាពជំនាញដែលសមល្មមអាចរស់នៅដោយឯករាជ្យយ៉ាងពេញលេញ ឬមានការធានាយ៉ាងពិតប្រាកដលើជីវភាព ។ (យោងតាមមាត្រាទី៧នៃបទបញ្ញត្តិអនុវត្តស្ដីពីច្បាប់សញ្ជាតិ មានតែអ្នកដែលទទួលបានអាជ្ញាប័ណ្ណជាស្ថាពរសំរាប់អាណិកជន ឬបំរុងនឹងចូលសញ្ជាតិតៃវ៉ាន់ នៅពេលស្នើសុំចូលសញ្ជាតិ មិនបាច់លិខិតបញ្ជាក់នេះ) ។ ៦. លិខិតបញ្ជាក់តាមប្រការទី៣អំពីស្តង់ដារទទួលស្គាល់សមត្ថភាពភាសាជាមូលដ្ឋាននិងចំណេះដឹងជាមូលដ្ឋានអំពីសិទ្ធិនិងភារកិច្ចរបស់ប្រជាពលរដ្ឋចំពោះអ្នកចូលសញ្ជាតិតៃវ៉ាន់ ។ ៧. សៀវភៅគ្រួសារដែលបានបំពេញបែបបទចុះបញ្ជីអាពាហ៍ពិពាហ៍រួចជាមួយប្ដីឬប្រពន្ធតៃវ៉ាន់យើង(សំណៅដើមនឹងសងវិញក្រោយការពិនិត្យ) ប្ដីឬប្រពន្ធជាជនតៃវ៉ាន់យើងមិនទាន់ចុះបញ្ជីគ្រួសារក្នុងស្រុក ហើយមិនទាន់បំពេញបែបបទចុះបញ្ជីអាពាហ៍ពិពាហ៍រួច ត្រូវតែផ្ដល់ភ្ជាប់ឯកសារបញ្ជាក់អាពាហ៍ពិពាហ៍(ធ្វើនៅក្រៅប្រទេស ត្រូវតែទទួលបញ្ជាក់ពីស្ថានទូតប្រចាំបរទេស បើឯកសារជាភាសាបរទេស ត្រូវតែផ្ដល់ភ្ជាប់នូវឯកសារបកប្រែជាភាសាចិន ដែលបានទទួលបញ្ជាក់ពីស្ថានទូតប្រចាំបរទេស ហើយទទួលបញ្ជាក់ពីសារការីក្នុងប្រទេស) ឯកសារបញ្ជាក់អត្តសញ្ញាណសញ្ជាតិ របស់ប្ដីនិងប្រពន្ធបរទេសនិងតៃវ៉ាន់យើង អ្នកដែលរៀបការនៅក្នុងស្រុក ត្រូវភ្ជាប់មកនូវលិខិតបញ្ជាក់សភាពអាពាហ៍ពិពាហ៍ ដែលមានការពិនិត្យបញ្ជាក់និងទទួលស្គាល់ពីស្ថាន ឯកអគ្គរដ្ឋទូតឬស្ថានកុងស៊ុលប្រចាំនៅប្រទេសក្រៅនិងឯកសារបកប្រែជាភាសាចិន ។ ៨. សោហ៊ុយធ្វើលិខិតបញ្ជាក់ ១០០០ យាន់តៃវ៉ាន់ថ្មី ។ (សូមបង់ដោយរូបិយាណត្តិប្រៃសណីយ៍ ហើយសរសេរអ្នកទទួលជាក្រសួងមហាផ្ទៃ) ។ ※ កំណត់ត្រាអំពីពេលវេលាចូលចេញពីព្រំដែន កំណត់ត្រាអំពីទោសឧក្រិដ្ឋកម្ម និងសំណៅសៀវភៅគ្រួសារដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍ជាមួយប្ដីឬប្រពន្ធជនតៃវ៉ាន់យើងរបស់អ្នកស្នើសុំ ត្រូវទទួលការត្រួតពិនិត្យពីអង្គការកិច្ចការអត្រានុកូលដ្ឋាន ។ ※ អ្នកដែលបានទទួលលិខិតបញ្ជាក់អនុញ្ញាតឱ្យចូលសញ្ជាតិតៃវ៉ាន់ ត្រូវតែប្រគល់លិខិតបញ្ជាក់ដូចជាកំណត់នៃខទី១ ទី២ ទី៣និងទី៨ ។
ការស្នើសុំលិខិតស្នាក់នៅ នៅតំបន់តៃវ៉ាន់	មន្ទីរគ្រប់គ្រងការចេញចូលដែននិងអន្តោប្រវេសន៍នៃនាយកដ្ឋានប៉ូលីសជាតិនៃក្រសួងមហាផ្ទៃ	១. សំណើសុំតាំងលំនៅ១សន្លឹក ។ ព្រមទាំង រូបថតពណ៌ធម្មជាតិ ១ សន្លឹក មិនទាន់ពាក់មួក(ទំហំតាមកំណត់អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋបច្ចុប្បន្ននេះ) ។ ២. សំណៅដើមនិងសំណៅចំលងនៃលិខិតអនុញ្ញាតឱ្យចូលសញ្ជាតិតៃវ៉ាន់ (សំណៅដើមនឹងសងវិញក្រោយការពិនិត្យ) ។ ៣. សំណៅដើមនិងសំណៅចំលងនៃប័ណ្ណស្នាក់នៅសំរាប់ជនបរទេស (សំណៅដើមនឹងសងវិញក្រោយការពិនិត្យ) ។ ៤. ឯកសារបញ្ជាក់អាស័យដ្ឋានស្នាក់នៅ ឧទាហរណ៍ សំណៅដើមនិងសំណៅចំលងនៃ សៀវភៅគ្រួសារដែលបានបំពេញបែបបទចុះបញ្ជីអាពាហ៍ពិពាហ៍រួចជាមួយប្ដីឬប្រពន្ធតៃវ៉ាន់យើង ឬអត្តសញ្ញាណប័ណ្ណពលរដ្ឋ (សំណៅដើមនឹងសងវិញក្រោយការពិនិត្យ) ៥. សោហ៊ុយធ្វើលិខិតបញ្ជាក់ ១០០០យាន់តៃវ៉ាន់ថ្មី ។
ការស្នើសុំតាំងលំនៅ នៅតំបន់តៃវ៉ាន់ (ត្រូវស្នាក់នៅពេញតាមពេលកំណត់ ចាប់ពីថ្ងៃអនុញ្ញាតស្នាក់នៅទៅ ត្រូវបន្តស្នាក់នៅ ១ ឆ្នាំ ឬស្នាក់នៅពេញ ២ ឆ្នាំ ហើយស្នាក់នៅហួស ២៧០ ថ្ងៃរាល់ឆ្នាំ ឬស្នាក់នៅពេញ ៥ ឆ្នាំ ហើយស្នាក់នៅហួស ១៨៣ ថ្ងៃរាល់ឆ្នាំ)	មន្ទីរគ្រប់គ្រងការចេញចូលដែននិងអន្តោប្រវេសន៍នៃនាយកដ្ឋានប៉ូលីសជាតិនៃក្រសួងមហាផ្ទៃ	១. សំណើសុំតាំងលំនៅ១សន្លឹក ។ (ប្រមទាំង រូបថតពណ៌ធម្មជាតិ ១ សន្លឹក មិនទាន់ពាក់មួក(ទំហំតាមកំណត់អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋបច្ចុប្បន្ននេះ) ។ ២. លិខិតស្នាក់នៅនៅតំបន់តៃវ៉ាន់ ។. ៣. សំណៅដើម និង ថតសៀវភៅគ្រួសារជនជាតិតៃវ៉ាន់នៃប្ដីឬប្រពន្ធ និង អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋតៃវ៉ាន់ ។.(សំណៅដើមនឹងសងវិញក្រោយការពិនិត្យ អ្នកលះលែងគ្នាមិនចាំបាច់ទេ) ៤. ការបញ្ជាក់លើការពិនិត្យសុខភាពមានលក្ខណសមស្របក្នុង៣ខែ ។.(ត្រូវពិនិត្យដោយ មន្ទីរពេទ្យដែលក្រសួងសុខាភិបាលនិងសង្គមកិច្ចយល់ព្រម ហើយសម្របតារាងទី២នៃតារាងប្រការត្រូវពិនិត្យដើម្បីការបញ្ជាក់លើការពិនិត្យសុខភាពដែលក្រុមរដ្ឋបាលកំណត់) ៥. ឯកសារបញ្ជាក់ដែលមានការពាក់ពន្ធទៀត ឧទាហរណ៍អ្នកស្នើសុំបានលែងលះជាមួយប្រជាជនតៃវ៉ាន់ ត្រូវផ្ដល់សំណៅដើមនិងសំណៅចំលងនៃក្រុយបត្រផ្ទះសម្បែងកំណត់ត្រាអាស័យដ្ឋានចុះបញ្ជីគ្រួសារត្រឹមត្រូវ ឬកិច្ចសន្យាជួល(សំណៅដើមនឹងសងវិញក្រោយការពិនិត្យ) ។ ៦. លិខិតអនុសិដ្ឋព្រមទាំងបំពេញឱ្យខានត្រឹមត្រូវនូវឈ្មោះអ្នកទទួលលិខិតនិងអាសយដ្ឋាន ។. ៧. សោហ៊ុយធ្វើលិខិតបញ្ជាក់ ៦០០ យាន់តៃវ៉ាន់ថ្មី ។
ការស្នើសុំចុះបញ្ជីស្ថិតិគ្រួសារនិងទទួលអត្តសញ្ញាណបណ្ណពលរដ្ឋ	ការិយាលិយកិច្ចការអត្រានុកូលដ្ឋាននៅតំបន់ចុះបញ្ជីគ្រួសារ	១. ច្បាប់ថតចំឡងនៃសេចក្ដីជូនដំណឹងរបស់មន្ទីរគ្រប់គ្រងការចេញចូលដែននិងអន្តោប្រវេសន៍នៃនាយកដ្ឋានប៉ូលីសជាតិនៃក្រសួងមហាផ្ទៃប្រទល់ជូនទៅអ្នកស្នើសុំឱ្យបំពេញ សក្តិកម្មតាំងលំនៅ ។. ២. សៀវភៅគ្រួសារ ។ (អ្នកមានតែម្នាក់ក្នុងគ្រួសារ មិនចាំបាច់ភ្ជាប់មកទេ ។ ប៉ុន្តែត្រូវលើឯកសារបញ្ជាក់ រួមទាំងសក្តិកម្មកម្មសិទ្ធិនៃផ្ទះរបស់អ្នកមានតែម្នាក់ក្នុងគ្រួសារ) ។ ៣. រូបថតមុខ ពណ៌ធម្មជាតិ មិនពាក់មួក ១ សន្លឹក បានថតនៅក្នុង ២ ឆ្នាំទើបកន្លងទៅ ទំហំនៃអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ សូមទៅទស្សនាវែបសាយពត៌មានពិភពលោកនៃមន្ទីរកិច្ចការអត្រានុកូលដ្ឋាននៃក្រសួងមហាផ្ទៃ http://www.ris. gov.tw/ស្វែងរកពត៌មានអំពីទំហំ) ។ ៤. អ្នកទទួលបញ្ជីពលរដ្ឋលើកទីមួយ ត្រូវបង់ប្រាក់ ៣០ យាន់តៃវ៉ាន់ថ្មី អ្នកទទួលអត្តសញ្ញាណប័ណ្ណលើកទីមួយ ត្រូវបង់ប្រាក់ ៥០ យាន់តៃវ៉ាន់ថ្មី ។ ※ ក្រោយពីការរាយការណ៍ការចុះបញ្ជីគ្រួសារ អ្នកស្នើសុំក៏អាចស្នើសុំទទួលអត្តសញ្ញាណប័ណ្ណតាមកំណត់ ពត៌មានមានពាក់ព័ន្ធ សូមទៅការិយាល័យកិច្ចការអត្រានុកូលដ្ឋាននៅតំបន់ចុះបញ្ជីគ្រួសារសួររកពត៌មាន ។